ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៥០០៣.....អពដ

# សេចក្តីបំភ្លឺ

អគ្គនាយកដ្ឋានពន្ធដារសូមធ្វើសេចក្តីបំភ្លឺឆ្លើយតបនឹងការចុះផ្សាយរបស់បណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុកមួយចំនួន ដែលថ្មីៗនេះ បានលើកឡើងបំផ្លើសខុសពីការពិត ទាក់ទងនឹងការដំឡើងឱ្យមានការយកពន្ធលើគ្រឹះស្ថានសិក្សា។

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនសាធារណជន ជាពិសេស មាតា-បិតា អាណាព្យាបាល និងសិស្ស-និស្សិត មេត្តាជ្រាបថា អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ ការប្រមូលពន្ធ-អាករផ្សេងៗ ត្រូវអនុវត្តលើការប្រកបអាជីវកម្មគ្រប់ប្រភេទ រួមទាំងការប្រកបអាជីវកម្មរបស់គ្រឹះស្ថានសិក្សា ផងដែរ។ កន្លងមក ដោយពិនិត្យឃើញថា វិស័យសិក្សាអប់រំគឺជាវិស័យអាទិភាពសំខាន់ និងជាមូលដ្ឋានក្នុងការអភិវឌ្ឍប្រទេសជាតិ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ផ្តល់ការលើកទឹកចិត្តលើវិស័យនេះ តាមរយៈការលើកលែងពន្ធអស់រយៈពេលជាច្រើនឆ្នាំមកហើយ ក្នុងនោះរួមមាន ការលើកលែងពន្ធលើប្រាក់ចំណេញ ការព្យួរទុកការប្រមូលអាករលើតម្លៃបន្ថែម និងការលើកលែងនូវទោសទណ្ឌផ្សេងៗមួយចំនួនដែលអគ្គនាយកដ្ឋានពន្ធដាររកឃើញថាគ្រឹះស្ថានសិក្សាទាំងនោះប្រកាសបង់ពន្ធមិនត្រឹមត្រូវ នាពេលកន្លងមក។

ដោយពិនិត្យឃើញថា គ្រឹះស្ថានសិក្សាភាគច្រើនជាសហគ្រាសស្វែងរកប្រាក់ចំណេញ មានការរីកចម្រើនខ្លាំង និងទទួលបានប្រាក់ចំណេញច្រើនគួរឱ្យកត់សម្គាល់ ដូច្នេះទើបរាជរដ្ឋាភិបាលសម្រេចមិនបន្តការលើកលែងពន្ធ-អាករ តាមការស្នើសុំរបស់គ្រឹះស្ថានសិក្សាទាំងនោះតទៅទៀត ហើយសម្រេចឱ្យចាប់ផ្តើមបំពេញកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញស្របតាមច្បាប់ ដូចសហគ្រាសដទៃៗទៀត ចាប់ពីឆ្នាំ២០១៦ នេះតទៅ។ ប៉ុន្តែរាជរដ្ឋាភិបាលនៅតែបន្តលើកលែងពន្ធអប្បបរមា ១% សម្រាប់រយៈពេល ០២ឆ្នាំបន្តទៀត រហូតដល់ដំណាច់ឆ្នាំ២០១៧។ **ដូច្នេះ ការដែលលើកឡើងថា រាជរដ្ឋាភិបាលដំឡើងពន្ធលើប្រាក់ចំណេញក្នុងវិស័យអប់រំសិក្សា នោះគឺជាការលើកឡើងមិនពិតនោះទេ។**

អគ្គនាយកដ្ឋានពន្ធដារសូមបញ្ជាក់ជូនសាធារណជន មាតា-បិតា អាណាព្យាបាល និងសិស្ស-និស្សិត មេត្តាជ្រាបផងដែរថា ពន្ធលើប្រាក់ចំណេញគឺជាពន្ធត្រូវប្រមូលពីចំណែកនៃប្រាក់ចំណេញ ដែលគ្រឹះស្ថានសិក្សា ក៏ដូចជាសហគ្រាសដែលប្រកបអាជីវកម្មផ្សេងទៀត ទទួលបានក្នុងឆ្នាំជាប់ពន្ធនីមួយៗ ក្រោយពីដកចំណាយរួចរាល់។ មានន័យថា ក្នុងករណីគ្រឹះស្ថានសិក្សាទាំងអស់នោះមានការខាតបង់នោះ រាជរដ្ឋាភិបាលក៏មិនតម្រូវឱ្យបង់ពន្ធលើប្រាក់ចំណេញនោះដែរ ប៉ុន្តែប្រសិនបើគ្រឹះស្ថានសិក្សាទទួលបានប្រាក់ចំណេញ គឺត្រូវមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋតាមអត្រា ២០% នៃប្រាក់ចំណេញដែលទទួលបាន។ ការបង់ពន្ធនេះគឺដើម្បីរួមចំណែកដល់ថវិកាជាតិសម្រាប់កសាង អភិវឌ្ឍ និងការពារប្រទេសជាតិ ហើយប្រាក់ពន្ធដែលត្រូវប្រមូលនេះ គឺមិនមែនជាបន្ទុកចំណាយរបស់សិស្ស-និស្សិត ឬមាតា-បិតា អាណាព្យាបាល នោះទេ។ នេះគឺជាកាតព្វកិច្ចបង់ពន្ធរបស់គ្រឹះស្ថានសិក្សា បន្ទាប់ពីទទួលបានការលើកទឹកចិត្តពន្ធអស់រយៈពេលច្រើនឆ្នាំមកហើយ។

ចំពោះអាករលើតម្លៃបន្ថែមដែលជាបន្ទុកផ្ទាល់របស់សិស្ស-និស្សិត ឬមាតា-បិតា អាណាព្យាបាល រាជរដ្ឋាភិបាលនៅតែបន្តរក្សាទុកការសម្រេចលើកលែងប្រមូលអាករលើតម្លៃបន្ថែម លើការបង់ថ្លៃសិក្សារបស់សិស្ស-និស្សិត ដដែល។

ដោយឡែក ចំពោះការផ្គត់ផ្គង់ទំនិញ និងសេវាក្រៅពីថ្លៃសិក្សា និងដែលមិនទាក់ទងនឹងថ្លៃសិក្សា គឺត្រូវជាប់ **"អាករលើតម្លៃបន្ថែម តាមអត្រា១០%"** ដែលការផ្គត់ផ្គង់ទាំងនោះរួមមាន ការជួលទីតាំងក្នុងសាលាដើម្បីប្រកបអាជីវកម្មផ្សេងៗ ការជួលបើកលក់អាហារដ្ឋាន ហាងកាហ្វេ ការស្នាក់នៅប្រចាំថ្ងៃ ការជួលរថយន្ត ការជួលបន្ទប់សម្រាប់រៀបចំសិក្ខាសាលា ជាដើម។ ការធ្វើអាជីវកម្មទាំងនេះក្នុងបរិវេណគ្រឹះស្ថានសិក្សា គឺត្រូវបំពេញកាតព្វកិច្ចសារពើពន្ធ ស្របតាមច្បាប់និងបទ

Collection by VCAT Professional Consultant

បទប្បញ្ញត្តិស្តីពីពន្ធដារ ដូចគ្នាទៅនឹងការធ្វើអាជីវកម្មនៅក្រៅបរិវេណគ្រឹះស្ថានសិក្សា ផងដែរ។ ប្រសិនបើអាជីវកម្មដែលស្ថិតក្នុងបរិវេណគ្រឹះស្ថានសិក្សាត្រូវបានលើកលែងពន្ធ នោះនឹងធ្វើឱ្យការអនុវត្តប្រមូលពន្ធមិនស្មើភាពគ្នា ចំពោះអាជីវកម្មដូចគ្នាដែលស្ថិតនៅក្រៅបរិវេណគ្រឹះស្ថានសិក្សា ដែលនាំទៅដល់ការប្រកួតប្រជែងមិនស្មើភាព។

អគ្គនាយកដ្ឋានពន្ធដារសូមស្វាគមន៍រាល់ការចុះផ្សាយរបស់សារព័ត៌មានទាំងឡាយណាដែលមានលក្ខណៈរិះគន់ក្នុងន័យស្ថាបនា រួមចំណែកលើកកម្ពស់ការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយតម្លាភាព និងសមភាព។ ព្រមជាមួយនេះ **ក៏សូមបដិសេធទាំងស្រុងចំពោះការលើកឡើងថា រាជរដ្ឋាភិបាលដំឡើងពន្ធលើប្រាក់ចំណេញក្នុងវិស័យអប់រំសិក្សាធិការ ដែលនេះគឺជាការលើកឡើងមិនពិត និងផ្ទុយពីគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទីប្រាំ នៃរដ្ឋសភាក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ ប្រកបដោយបញ្ញាញាណ គតិបណ្ឌិត របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ដែលបានដាក់ចេញនូវយុទ្ធសាស្ត្រកៀរគរចំណូលពន្ធ តាមរយៈការខិតខំប្រមូលឱ្យបានអស់លទ្ធភាព សក្តានុពលដែលមានស្រាប់ ក្នុងបរិបទនៃការមិនបង្កើតប្រភេទពន្ធថ្មី និងការមិនដំឡើងអត្រាពន្ធ។**

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន មាតា-បិតា អាណាព្យាបាល និងសិស្ស-និស្សិតទាំងអស់មេត្រាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦

**អគ្គនាយកដ្ឋានពន្ធដារ**

Collection by VCAT Professional Consultant